រាជធានីភ្នំពេញ ,ថ្ងៃទី១២ ខែមេសា ឆ្នាំ ១៩៩៩

# សេចក្ដីសំរេចលេខ ៣៧ សសរ

## ស្ដីពីការបង្កើតគណៈកម្មការដោះស្រាយ ទីតាំង និង ជួសជុលប្ញទីកីឡា

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : ប្រគល់ភារកិច្ច ដើម្បីដោះស្រាយទីតាំង និង ជួសជុលប្ញទីកីឡាដល់គណៈកម្មការ ដែលមាន សមាសភាពដូចខាងក្រោម :

១-ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ប្រធាន

២-ឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ អនុប្រធាន

៣-ឯកឧត្តម មី សាមឺឌី អនុប្រធានទី១ នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន

៤-ឯកឧត្តម ប៉ុក ថន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា អនុប្រធាន

៥-ឯកឧត្តម វ៉ន សារិន អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូនិយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

៦-លោកជំទាវ ស៊ិន សុី អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ

៧-ឯកឧត្តម ខី តាឃី អនុរដ្ឋលេខាធិការក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨-ឯកឧត្តម ម៉ម សុផាណា អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សមាជិក

៩-ឯកឧត្តម លី យីម៉ុន អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១០-ឯកឧត្តម ចេវ គីមហេង អភិបាលរងរាជធានីភ្នំពេញ សមាជិក

១១-លោក មាស សារិន អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

១២-លោក ណុប ស៊ីណូ ប្រធាននាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់ សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដោះស្រាយការងារដូចខាងក្រោមនេះ :

- ដោះស្រាយទីតាំងបរិវេណបូរីកីឡា សំរាប់ធ្វើការជួសជុលក្នុងក្របខ័ណ្ឌ ជំនួយឧបត្ថម្ភរបស់ភាគីសាធារណរដ្ឋប្រជាមានិតចិន ។
- លើកវិធានការដោះស្រាយ យកប្រជាពលរដ្ឋដែលស្នាក់នៅក្នុងបរិវេណបូរីកីឡាឲ្យចាកចេញពីទីតាំងបូរីកីឡាទាំងមូល ដោយស្រាវជ្រាវស្រង់ស្ថិតិពិតប្រាកដតាមប្រភេទអ្នកដែលរស់នៅក្នុងបរិវេណបូរីកីឡាតាមដំណាក់កាលពេលវេលាដែលបានស្នាក់នៅ ដោយដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យក្នុងបរិវេណបូរីកីឡាព្រមទាំងដោះស្រាយយកទីតាំងដែលជួលអោយទូរទស្សន៍បុស្តិ៍លេខ៥ និងកំណត់ប្រភេទនៃការដោះស្រាយប្រាក់ឧបត្ថម្ភ ។
- ធ្វើជាដៃគូរពិភាក្សាជាមួយភាគីចិន ដើម្បីកសាងភូមិ និងសាងសង់លំនៅដ្ឋានសំរាប់ឲ្យប្រជាពលរដ្ឋ ដែលរផ្លេរពីបូរីកីឡាទៅស្នាក់នៅ ។
- ដោះស្រាយផ្ទះសំបែង និង ប្រាក់ឧបត្ថម្ភជូនគ្រួសារប្រជាពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅចេញពីបូរីកីឡា
- ចូលរួមក្នុងការរៀបចំផ្លែសំណង់ ដែលមកជួសជុលនិងសាងសង់បូរីកីឡា ។
- ត្រួតពិនិត្យសកម្មភាព និង ដំណើរការជួសជុលបូរីកីឡា ។
- ពិភាក្សាសំរបសំរួលវេណទាន ប្រើប្រាស់ក្នុងការជួសជុលបូរីកីឡា និង ជ្រើសរើសសហគ្រិនសំណង់ដែលមានស្នាដៃក្នុងការសាងសង់ជួសជុលបូរីកីឡា ជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន
- ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងាររបស់គណៈកម្មការជូនរាជរដ្ឋាភិបាល

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធបង្កើតអនុគណៈកម្មការឬ ក្រុមការងារមួយចំនួន ដើម្បីជាជំនួយការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាការធិការជាតិអូឡាំពិក ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវអស់លោកដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***